វគ្គទី ៤

# ចេញពីការពឹងផ្អែកលើជំនួយ ឆ្ពោះទៅកាន់វិបុលភាពរួមៈ ការគ្រប់គ្រងធនធានប្រេងឥន្ធនៈ និងឧស្ម័ននៅកម្ពុជា

**បណ្ឌិត សុខ ស៊ីណា**

អ្នកស្រាវជ្រាវនៅ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីគោរព ។ ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ថ្លៃថ្លា ដោយបានចូលរួមជាវាគ្មិនក្នុងសន្និសីទស្តីពីចក្ខុវិស័យឆ្នាំ២០០៧ អំពីប្រធានបទ *ចេញពីការពឹងផ្អែកលើជំនួយ ឆ្ពោះទៅកាន់វិបុលភាពរួមៈ ការគ្រប់គ្រងធនធានប្រេងឥន្ធនៈ និងឧស្ម័ននៅកម្ពុជា* ។ វិទ្យាស្ថាន CDRI មានជំនឿយ៉ាងមុតមាំថា ចំណូលប្រេងកាត ជាកាលានុវត្តភាពមួយដ៏ប្រពៃបំផុតសំរាប់ប្រែក្លាយសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា ឈានទៅរកវិបុលភាព ។

នៅក្នុងបទបង្ហាញរបស់ខ្ញុំថ្ងៃនេះ ខ្ញុំនឹងនិយាយអំពីលទ្ធភាពវិនិយោគនៃចំណូលប្រេង ពីហានិភ័យនៃការគ្រប់គ្រងចំណូលប្រេង និងយុទ្ធសាស្រ្តសំរាប់ថ្ងៃអនាគត ធ្វើយ៉ាងណាដើម្បីអោយចំណូលប្រេង បំរើដល់ផលប្រយោជន៍ប្រជាជន ។

## កាលានុវត្តភាពនៃវិនិយោគពីផលប្រេងកាត

- ការរកឃើញ និងផែនការខួងយករ៉ែប្រេងកាត និងឧស្ម័ននៅឆ្នាំ២០០៨-២០០៩ ខាងមុខនេះ ជាឱកាសដ៏ប្រសើរបំផុតសំរាប់ប្រទេសកម្ពុជា ក្នុងកាលៈទេសៈដែលតំលៃប្រេងនៅលើទីផ្សារអន្តរជាតិ កំពុងមានតំលៃខ្ពស់ ហើយកម្ពុជាកំពុងពឹងផ្អែកខ្លាំងលើជំនួយបរទេស ។ ពិសេសជាងនេះទៀត ប្រភពចំណូលប្រេងកាត នឹងជួយស្តារឱនភាពចំណូល ព្រោះពន្ធគយមួយចំនួន នឹងត្រូវបាត់បង់ ដោយសារតែសមាជិកភាពនៅក្នុងអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក ដែលតំរូវអោយកម្ពុជា បញ្ចុះអត្រាពន្ធគយ ។ និយាយជារួម ចំណូលប្រេងកាតនឹងក្លាយទៅជាប្រភពដ៏សំខាន់ សំរាប់បំរើដល់កំណើនសេដ្ឋកិច្ច ដោយយកទៅវិនិយោគលើផ្លូវជាតិ អគារសាធារណៈ ស្ថាប័នអប់រំ វិស័យសុខាភិបាល និងវិនិយោគវិស័យកសិកម្ម លើការកសាងផ្លូវជនបទ ប្រព័ន្ធធារាសាស្រ្ត ប្រព័ន្ធផ្សព្វផ្សាយ កែលំអវិធីដាំដុះ និងគ្រាប់ពូជ ។ វិនិយោគលើផ្នែកទាំងនេះ សំដៅបំរើ និងធានាដល់កំណើនសេដ្ឋកិច្ច ក្នុងពេលបច្ចុប្បន្ន ក៏ដូចជាទៅថ្ងៃអនាគត ។
- ចំណូលប្រេងអាចប្រើប្រាស់ ដើម្បីពង្រឹងប្រព័ន្ធសង្គមកិច្ច ដោយបង្កើតមូលនិធិសង្គមកិច្ច និងបង្កើនមូលនិធិសោធននិវត្តន៍ ។
- ចំណូលប្រេងជាឱកាសដ៏ល្អរបស់រាជរដ្ឋាភិបាលក្នុងកំណែទំរង់សារធារណៈ ដោយលើកកំពស់ប្រាក់បៀវត្សរ៍ បង្កើនសមត្ថភាព និងធ្វើទំនើបកម្មសំភារៈបរិក្ខាររដ្ឋបាល ។
- ម្យ៉ាងវិញទៀត ចំណូលប្រេង អាចជាឱកាសមួយបំរើដល់ការផ្តួចផ្តើមឧស្សាហកម្ម និងសិប្បកម្មក្នុងស្រុក ដើម្បីកាត់បន្ថយការពឹងផ្អែកលើការនាំចូល និងបង្កើតការងារ ជូនដល់ប្រជាពលរដ្ឋ ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ចំណូលប្រេងកាតអាចមានផលប៉ះពាល់វិជ្ជមានផង និងអវិជ្ជមានផង ។ បទពិសោធន៍ក្នុងប្រទេសនានាបង្ហាញថា ចំណូលបានពីធនធានធម្មជាតិ ជាទ្រព្យលាភផង និងជាទ្រព្យឧបទ្រពផង ។ ប្រទេសនីហ្សេរីយ៉ា សាធារណៈរដ្ឋកុងហ្គោ និងអង់ហ្គោឡាសំបូររ៉ែធម្មជាតិ ដូចជា មាស ពេជ្រ ប្រេងកាត និងឧស្ម័ន ក៏ប៉ុន្តែប្រទេសទាំងនោះ ពុំមានការលូតលាស់រីកចំរើនឡើយ ។ រីឯប្រទេសសំបូររ៉ែធម្មជាតិ ដូចជា ន័រវ៉េស កាណាដា ឥណ្ឌូនេស៊ី និង ម៉ាឡេស៊ី បានទាញយកផលប្រយោជន៍ពីធនធានធម្មជាតិទាំងនោះ ដើម្បីយកទៅអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន បានដោយជោគជ័យ ។

ជាទូទៅ ប្រទេសសំបូរភោគផលធម្មជាតិ ច្រើនតែមានកំណើនសេដ្ឋកិច្ច ទាបជាងប្រទេសដែលពុំសំបូរភោគផលធម្មជាតិ ។ ដើម្បីទាញយកឧត្តមប្រយោជន៍ពីចំណូលប្រេងកាត និងឧស្ម័នធម្មជាតិ កម្ពុជាត្រូវតែត្រៀមខ្លួនអោយបានល្អបំផុត ដោយរៀនសូត្រយកបទពិសោធពីប្រទេសដែលទទួលបានជោគជ័យពីចំណូលប្រេងផង និងពីប្រទេសដែលពុំបានទាញយកប្រយោជន៍ពីចំណូលប្រេងផង ។

## ហានិភ័យនៃការគ្រប់គ្រងចំណូលប្រេងកាត

ខ្ញុំសូមអនុញ្ញាតលើកយកហានិភ័យចំនួន ៣ ដែលទាក់ទងនឹងការគ្រប់គ្រងចំនូលប្រេងកាត មកជំរាបជូនអង្គសន្និសីទៈ

**ហានិភ័យទី១** ទាក់ទងនឹង ជំងឺហូឡង់ (Dutch Disease) រី ជាវិបត្តិសេដ្ឋកិច្ចមួយកើតនៅប្រទេសហូឡង់នៅរវាងឆ្នាំ១៩៦០ ក្នុងពេលដែលប្រទេសហូឡង់បានទទួលប្រាក់ចំណូលដ៏សន្ធឹកសន្ធាប់ពីការនាំចេញរ៉ែប្រេងកាត និងឧស្ម័នធម្មជាតិ ។ ជំងឺហូឡង់នេះ អាចពន្យល់ដោយសង្ខេបថា ជាការធ្លាក់ចុះនៃផលិតកម្មក្នុងស្រុកផ្សេងៗដែលបំរើដល់ការនាំចេញ ។ រូបិយវត្ថុក្នុងស្រុក (Guilder) កើនតំលៃតំរូវការនៃផ្នែកសេវាកម្ម និងសំណង់កើនឡើងខ្លាំង និងបានបង្កើតការងារជាច្រើន ។ ស្ថានភាពសេដ្ឋកិច្ចបានក្រឡាប់ចាក់ ខណៈដែលតំលៃប្រេងធ្លាក់ចុះនៅពាក់កណ្តាលឆ្នាំ១៩៨០ ធ្វើឱ្យចំណូលប្រេងថយចុះយ៉ាងខ្លាំង រួចក៏ប្រទាញតំរូវការនៃផ្នែកផ្សេងៗអោយថយចុះ ហើយបណ្តាលអោយមានកំណើននិកម្មភាព (ភាពគ្មានការងារធ្វើ) ។

ជាទូទៅ ផលអវិជ្ជមាននៃជំងឺហូឡង់នេះ បានកើតឡើងនៅស្ទើរតែគ្រប់ប្រទេសទាំងអស់ដែលមានចំណូលធនធានធម្មជាតិច្រើន ។

**ហានិភ័យទី២** គឺឧស្សាហកម្មប្រេងកាតជា *ឧស្សាហកម្មទោល* ពុំបានជួយយិតយោងឧស្សាហកម្មឯទៀតអោយរីតលូតលាស់ដូចខ្លួនបានឡើយ ។ ឧស្សាហកម្មនេះ ទំនើប ប្រើប្រាស់ធនធានក្នុងស្រុកតិចបំផុត ហើយពុំផ្សារភ្ជាប់នឹងផ្នែកឯទៀតឡើយ ។ បច្ចេកវិទ្យា និងបរិក្ខារស្ទើរតែទាំងអស់ ត្រូវបាននាំចូល ។ ប្រហែលជាមកពីកត្តាទាំងអស់នេះហើយដែលធ្វើអោយប្រទេសផលិតប្រេងមួយចំនួន ពុំសូវយកចិត្តទុកដាក់លើកស្ទួយ និងពង្រីកវិស័យអប់រំ ។ សូមបញ្ជាក់ថា វិស័យអប់រំជាគន្លឹះអភិវឌ្ឍន៍ដ៏ចំបងបំផុត ។

**ហានិភ័យទី៣** គឺអំពើពុករលួយៈ គេសង្កេតឃើញថា ចំណូលដែលបានមកងាយស្រួលពីធនធានធម្មជាតិ អាចបណ្តាលអោយប្រទេសនោះ មានអំពើពុករលួយកាន់តែធ្ងន់ធ្ងរឡើងៗ ។ ប្រទេសនីហ្សេរីយ៉ាជាឧទាហរណ៍យ៉ាងជាក់ស្តែង ចំណូលរ៉ែប្រេងកាត និងឧស្ម័នមួយផ្នែកធំ ត្រូវបានបែងចែកក្នុងចំណោមឥស្សរជនសំខាន់ៗ និងប្រើប្រាស់

ដើម្បីពង្រឹងរបបគ្រប់គ្រងនៃប្រទេសនេះ ។ អ្នកសេដ្ឋកិច្ចមួយចំនួនបានអះអាងថា ប្រទេសនីហ្សេរីយ៉ា នឹងមានការលូតលាស់ប្រសើរជាងនេះ ប្រសិនបើប្រទេសនេះ ឈប់ផលិតប្រេង រឺក៏ចំណូលប្រេងទាំងអស់ ត្រូវបានបែងចែកដល់ពលរដ្ឋនីហ្សេរីយ៉ាទាំងអស់គ្នា ។ ទោះបីមានចំណូលប្រេង និងឧស្ម័នដ៏មហាសាលក៏ដោយ ប៉ុន្តែអំពើមហាពុករលួយ និងជំងឺហូឡង់ បានបំផ្លាញសេដ្ឋកិច្ច និងបង្កើនភាពក្រីក្រនៃប្រទេសនេះ ។ ដើម្បីជៀសវាងបញ្ហាដូចបានកើតមាននៅប្រទេសនីហ្សេរីយ៉ានេះ កម្ពុជាគួរតែអនុម័តច្បាប់ប្រឆាំងអំពើពុករលួយអោយបានឆាប់រហ័ស ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ផ្អែកលើបទពិសោធន៍ទាំងអស់នេះ ផលប៉ះពាល់អវិជ្ជមាន នឹងកើតមានឡើងក្នុងប្រទេសកម្ពុជា ប្រសិនបើឧស្សាហកម្មប្រេងកាតផ្តល់ចំណូល ហើយចំណូលទាំងនោះពុំបានគ្រប់គ្រងប្រកបដោយតំលាភាព និងប្រសិទ្ធិភាពទេនោះ ។ តំលៃទូទៅនៃទំនិញឡើងខ្ពស់ និងកំណើនតំលៃប្រាក់រៀល ប៉ះពាល់ដល់ការប្រកួតប្រជែង ដោយសារតំលៃដើមទំនិញឡើងខ្ពស់ ។ ទំនិញកសិកម្ម ដូចជាស្រូវអង្ករ គ្រាប់ធញ្ញជាតិ និងទំនិញឧស្សាហកម្មកាត់ដេរ ងាយរងឥទ្ធិពលអវិជ្ជមានពីចំណាយនៃផលប្រេងកាត ដោយសារភាពប្រកួតប្រជែងនៃទំនិញផ្នែកនេះ ពឹងផ្អែកខ្លាំងលើកត្តាតំលៃ ។ ប្រសិនបើផ្នែកនេះ រងនូវការប៉ះទង្គិច និកម្មភាពនឹងកើនឡើង ហើយជះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ចជាតិទាំងមូល ។ ម៉្យាងវិញទៀត តំលៃដីធ្លី ផ្ទះ និងអគារ នឹងកើនឡើង ប្រសិនបើចំណូលប្រេងកាត ត្រូវបានចាយវាយខ្លាំងលើផ្នែកនេះ ។ កម្ពុជានឹងក្លាយជាប្រទេសដែលមានតំលៃខ្ពស់សំរាប់ជីវភាពរស់នៅ ក៏ដូចជាសំរាប់ការធ្វើវិនិយោគ ។

ថ្វីត្បិតតែមានផលប៉ះពាល់អវិជ្ជមានទាក់ទងនឹងចំណូលប្រេងកាតខ្លះមែន ប៉ុន្តែចំណូលប្រេងកាត ក៏អាចធ្វើអោយមានកំណើនសេដ្ឋកិច្ចប្រកបដោយសមភាព និងកាត់បន្ថយភាពក្រីក្របានឆាប់រហ័សដែរ ។

## យុទ្ធសាស្ត្រសំរាប់ថ្ងៃអនាគត

ដើម្បីទប់ស្កាត់ផលអាក្រក់ទាំងឡាយ ដូចបានរៀបរាប់ពីខាងដើម និងដើម្បីទាញយកប្រយោជន៍ពីធនធានធម្មជាតិសំដៅបំរើអោយនយោបាយអភិវឌ្ឍ ខ្ញុំបាទសូមអនុញ្ញាតលើកយកអនុសាសន៍មួយចំនួនដែលបានអនុវត្តដោយជោគជ័យក្នុងបណ្តាប្រទេសមួយចំនួនមកបង្ហាញ:

- ទប់ស្កាត់កំណើនតំលៃរូបិយវត្ថុក្នុងស្រុក និងទប់ស្កាត់កំណើនតំលៃទំនិញក្នុងស្រុក ដោយជៀសវាងការចាយវាយចំណូលប្រេងគំហុកទៅក្នុងទីផ្សារ និងប្រើចំណូលប្រេងកាត់រំលោះបំណុល ។
- ជំរុញការពង្រីកមូលដ្ឋានផលិតកម្ម ដើម្បីកាត់បន្ថយការពឹងផ្អែកលើផ្នែកថាមពល និងដើម្បីសំរាលផលប៉ះពាល់អវិជ្ជមាននៃជំងឺហូឡង់ ។
- ចំណូលប្រេងមួយផ្នែក ត្រូវរក្សាទុកក្នុងមូលនិធិប្រេង ដើម្បីធានាបានចីរភាពចំណាយ ក្នុងខណ:ដែលចំណូលប្រេងស្រុតចុះ ដោយសារភាពរអាក់រអួលនៃផលិតកម្ម រឺក៏តំលៃប្រេងធ្លាក់ចុះ និងដើម្បីអន្តរាគមន៍ក្នុងទីផ្សាររូបិយប័ណ្ណ ។ វិធានការចុងក្រោយ គឺជួយរក្សាលំនឹងរូបិយវត្ថុក្នុងស្រុក ។
- វិធានការទាំងអស់នេះ ទាមទារឱ្យមានការបង្កើតគណ:កម្មការមូលនិធិប្រេងកាត ដោយប្រកាន់ខ្ជាប់គោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធិភាព ។ ដូច្នេះ ការចូលរួមក្នុងសមាគមគំនិតផ្តួចផ្តើម

ដើម្បីតម្លាភាពនៃឧស្សាហកម្មប្រេង (Extractive Industry Transparency Initiative) គឺជាការចាំបាច់ ។ គោលបំណងចំបងនៃសមាគមនេះ គឺជួយពង្រឹងតម្លាភាព និងគណនេយ្យភាពនៃចំណូលប្រេងក្នុងបណ្តាប្រទេសផលិតប្រេងទាំងឡាយ ដើម្បីអោយប្រទេសទាំងនោះរួចផុតពីផលអវិជ្ជមាននានា ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ថ្វីត្បិតតែមានផលប៉ះពាល់អវិជ្ជមានខ្លះ ទាក់ទងនឹងឧស្សាហកម្មប្រេងក៏ពិតមែន ក៏ប៉ុន្តែជោគជ័យ រឺក៏បរាជ័យនៃឧស្សាហកម្មនេះ អាស្រ័យទាំងស្រុងលើការគ្រប់គ្រង និងការប្រើប្រាស់ចំណូលប្រេងប្រកបដោយមាន រឺក៏គ្មានតំលាភាព និងប្រសិទ្ធិភាព ។ វិទ្យាស្ថាន CDRI មានជំនឿយ៉ាងមុតមាំថា ចំណូលប្រេងនៅកម្ពុជា នឹងត្រូវបានគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដើម្បីបំរើដល់ផលប្រយោជន៍ប្រជាជនគ្រប់ៗគ្នា ។

សូមអរគុណ